ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

**លេខ និង ឈ្មោះសំណុំរឿង : ៤៤/០៩ - សៅធនី បើរ**

**កាលបរិច្ឆេទនៃសេចក្តីបង្គាប់ : ថ្ងៃទី០៩ ខែមេសា ឆ្នាំ២០០៩**

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា៣១៣នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជកៈ **ឈើវ ភិរម្យ**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិតៈ **លីវ សុវណ្ណា**

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើៈ **អាំង អេងថុង**

## ភាគីនៃវិវាទ

១- ភាគីនិយោជក

ឈ្មោះ : **ក្រុមហ៊ុន សៅធនី បើរ**

អាសយដ្ឋាន : សួនវិឡូនៈ សង្កាត់ចោមចៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ

ទូរស័ព្ទ : ០១២ ៣៨៥ ៧០៥ ទូរសារ : គ្មាន

តំណាងភាគីនិយោជក :

| | |
|---|---|
| ១- លោកស្រី Sung Guo Hong | ប្រធានរដ្ឋបាលក្រុមហ៊ុន |
| ២- លោកស្រី ជា សុវណ្ណច័ន្ទសម្បត្តិ | ជំនួយការរដ្ឋបាល |
| ៣- លោក ស្រ៊ាន ចុន្ទី | ជំនួយការរដ្ឋបាល |
| ៤- លោក Wu Jian Ji | មេការ |

២- ភាគីកម្មករនិយោជិត

**ឈ្មោះ : សហព័ន្ធសហជីពកម្មករកម្ពុជា-សហជីពកម្មករនិយោជិតនៃរោងចក្រកាត់ដេរ សៅធនី បើរ**

អាសយដ្ឋាន : បុរីសឡា ភូមិត្រពាំងឈូក សង្កាត់ទឹកថ្លា ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ

លេខទូរស័ព្ទ : ០១៦ ៦៩៧ ៥៥៦ លេខទូរសារ : គ្មាន

តំណាងកម្មករនិយោជិត:

| | | |
|---|---|---|
| ១- | លោក ឃិន សុខន | អគ្គលេខាធិការសហព័ន្ធសហជីពកម្មករកម្ពុជា |
| ២- | លោក អាន សារឿន | អនុប្រធានសហជីពកម្មករនិយោជិត (Golden Grown) |
| ៣- | លោក ខឹម មាស | ទីប្រឹក្សាសហជីពកម្មករនិយោជិត (Golden Grown) |
| ៤- | លោក ផេន ភិណា | អនុប្រធានទី១ សហជីពកម្មករនិយោជិត (Golden Grown) |
| ៥- | លោក ម៉ៅ សារឿន | អគ្គលេខាធិការរង សហជីពកម្មករនិយោជិត |
| ៦- | លោក គឹម សារ៉ង | ទីប្រឹក្សាសហជីពកម្មករនិយោជិត |
| ៧- | លោក យ៉ង យាន់ | លេខាសហជីពកម្មករនិយោជិត |
| ៨- | លោក ធន វាសនា | ទីប្រឹក្សាសហជីពកម្មករនិយោជិត |

## បញ្ហាវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

កម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនផ្តល់ប្រាក់ឈ្នួលមួយរយភាគរយ និងអត្ថប្រយោជន៍ផ្សេងៗជូនកម្មករនិយោជិត នៅពេលក្រុមហ៊ុនគ្មានការងារឱ្យធ្វើ(ព្យួរការងារ) ក្នុងករណីគ្មានការអនុញ្ញាតពីក្រសួង។ ដោយឡែកភាគីនិយោជកបញ្ជាក់ថា ក្រុមហ៊ុនមិនមានលទ្ធភាពផ្តល់ប្រាក់ឈ្នួលឱ្យមួយរយភាគរយបានឡើយ នៅពេលព្យួរការងារកម្មករ គឺក្រុមហ៊ុនផ្តល់ឱ្យដូចខាងក្រោម:

១- ប្រាក់ថ្លៃជួលផ្ទះស្នាក់នៅចំនួន ០៨ ដុល្លារអាមេរិកក្នុងមួយខែ

២- ប្រាក់ទ្រទ្រង់ជីវភាពចំនួន ០៦ ដុល្លារអាមេរិកក្នុងមួយខែ

៣- ប្រាក់អតីតភាពការងារតាមចំនួនឆ្នាំរបស់កម្មករធ្វើការបាន។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ (ខ)(មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល លេខ ០៩៩ សកបយ ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាស លេខ ០៩៩ សកបយ ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៧៦/០៧ កកបវ./ប្រក ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ ២០០៧ (អាណត្តិទី៥)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី ២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ

ហើយរបាយការណ៍ស្តីអំពីការមិនសះជា លេខ ២២៤ កប/អក/វ.ក ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០៩ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០០៩។

**សវនាការ និង សន្ទនីតិវិធីមុនពេលក្រុមប្រឹក្សាអាជ្ញាកណ្តាល**

**ទីកន្លែងសវនាការ :** ក្រុមប្រឹក្សាអាជ្ញាកណ្តាល មជ្ឈមណ្ឌលភ្នំពេញ អគារ A វិថីសុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទសវនាការ :** ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០០៩ ( វេលាម៉ោង ១៤:00 នាទី រសៀល) ។

**បញ្ហានៃនីតិវិធី**

នៅថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០០៩ នាយកដ្ឋានវិវាទការងារបានទទួលពាក្យបណ្តឹងរបស់សហជីពកម្មករនិយោជិតរោងចក្រ សៅធន៍ ប៊ែរ ដែលទាមទារចំនួន០១ចំណុច គឺទាមទារឱ្យក្រុមហ៊ុនផ្តល់ប្រាក់ឈ្នួល១០០% និងអត្ថប្រយោជន៍ផ្សេងៗជូនកម្មករនិយោជិតនៅពេលក្រុមហ៊ុនគ្មានការងារឱ្យធ្វើ( ព្យួរកិច្ចសន្យាការងារ) ដោយគ្មានការអនុញ្ញាតពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ នាយកដ្ឋានវិវាទការងារបានធ្វើការផ្សះផ្សាវិវាទនេះនៅថ្ងៃទី១៦ ខែមីនា ឆ្នាំ២០០៩ ដោយមិនបានទទួលលទ្ធផលសះជាទេ លើការទាមទារចំនួន០១ចំណុច ហើយចំណុចមិនសះជាចំនួន០១ចំណុចនេះ ត្រូវបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅថ្ងៃទី២០ ខែមីនា ឆ្នាំ ២០០៩។

បន្ទាប់ពីបានទទួលសំណុំរឿងរួចមក លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានធ្វើការកោះអញ្ជើញភាគីក្រុមហ៊ុន និងភាគីកម្មករនិយោជិតឱ្យចូលរួមសវនាការ នៅថ្ងៃទី២៧ ខែមីនា ឆ្នាំ២០០៩។

នៅថ្ងៃទី២៧ ខែមីនា ឆ្នាំ២០០៩ វេលាម៉ោង១៤:00នាទីរសៀល ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានបើកសវនាការ ដើម្បីដំណើរការអាជ្ញាកណ្តាលដោះស្រាយវិវាទដែលមិនទាន់សះជានេះ។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានលើកទឹកចិត្តដល់ភាគីទាំងពីរឱ្យបន្តការចរចាទាំងនៅក្នុងសវនាការ ទាំងនៅក្នុងសបព្រាស ដើម្បីស្វែងរកដំណោះស្រាយមួយតាមរយៈការផ្សះផ្សា ហើយបានព្យាយាមផ្សះផ្សាវិវាទនេះ តែគូភាគីមិនបានសះជាទេ ទើបក្រុមប្រឹក្សាអាជ្ញាកណ្តាលលើកយកចំណុចវិវាទនេះមកពិចារណានៅក្នុងសេចក្តីបង្គាប់នេះ។

**ភស្តុតាង**

**សាក្សី និង អ្នកជំនាញក្រៅពីភាគី : គ្មាន**

**ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន**

**ក- ឯកសារបានទទួលពីភាគីនិយោជក :**

១- លិខិតផ្ទេរសិទ្ធិរបស់នាយកក្រុមហ៊ុនជូនលោកស្រី Sun Guo Hong ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ ២០០៩។

២- សេចក្តីប្រកាសជូនដំណឹងបើកសហគ្រាសនៃយីហោសហគ្រាស សៅធន៍ ប៊ែរ ចុះបញ្ជិកាលេខ ៣៤២ ក.ប.វ/អក ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០០៤។

៣- លិខិតរបស់ប្រធាននាយកដ្ឋានអធិការកិច្ចការងារ ជម្រាបទៅលោកនាយកក្រុមហ៊ុន សៅធន៍ ប៊ែរ ស្តីពីការព្យួរកិច្ចសន្យាការងារកម្មករនិយោជិត លេខ ១១៩៣ កប/អក/អធក. ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ ២០០៨។

៤- លិខិតរបស់នាយកក្រុមហ៊ុន សៅធន៍ ប៊ែរ គោរពជូនប្រធាននាយកដ្ឋានអធិការកិច្ចការងារ ស្តីពីសំណើសុំព្យួរការងារកម្មករនិយោជិតបន្តចំនួន០២ខែ ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០០៩។

៥- បទបញ្ជាផ្ទៃក្នុងក្រុមហ៊ុន សៅធន៍ ប៊ែរ លេខ ៤៧ ក.ក.ប.វ/អក ចុះថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០០៩។

**ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖**

១- វិញ្ញាបនប័ត្របញ្ជាក់ភាពជាតំណាងបំផុតរបស់សហជីពកម្មករនិយោជិតនៃរោងចក្រ សៅធន៍ ប៊ែរ លេខ ០៦៥/០៨ ក.ប. ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០៨។

២- វិញ្ញាបនប័ត្របញ្ជាក់ភាពជាតំណាងបំផុតរបស់សហជីពកម្មករនិយោជិតនៃរោងចក្រ ហ្គោលឌិន ក្រោន លេខ ០៦២/០៨ ក.ប ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០៨។

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន សៅធន៍ ប៊ែរ លេខ ២២៤ កប/កណ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៩។

២- កំណត់ហេតុដោះស្រាយវិវាទការងាររួមរបស់ក្រុមហ៊ុន សៅធន៍ ប៊ែរ ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០០៩។

**ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល**

១- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការ លេខ ១៨៦ កប/អក/វក/លកអ. ចុះថ្ងៃទី ២៣ ខែមីនា ឆ្នាំ២០០៩។

២- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការ លេខ ១៨៥ កប/អក/វក/លកអ. ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០០៩។

**អង្គហេតុ**

- ក្រោយពីបានពិនិត្យលើកំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្តាប់អំណះអំណាងរបស់ភាគីនិយោជក និងកម្មករនិយោជិត
- ក្រោយពីបានពិនិត្យឯកសារ និងភស្តុតាងផ្សេងៗ

**ក្រុមប្រឹក្សាអាជ្ញាកណ្ដាលរកឃើញថា៖**

នៅក្នុងក្រុមហ៊ុន សៅធន៌ បើរ អ៊ិនធើប្រាយស៏ កូ អិលធីឌី មានកម្មករនិយោជិតសរុបប្រហែល៦០០នាក់ ហើយនៅក្នុងក្រុមហ៊ុននេះ មានតែសហជីពកម្មករនិយោជិតរោងចក្រ សៅធន៌ បើរ តែមួយប៉ុណ្ណោះ ហើយសហជីពនេះ ទទួលបានភាពជាតំណាងបំផុតនៅក្នុងសហគ្រាស ដោយមានវិញ្ញាបនប័ត្របញ្ជាក់ភាពជាតំណាងបំផុតពីក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ លេខ ០៦៥/០៨ ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០៨។

**ចំណុចវិវាទ: ភាគីកម្មករនិយោជិតទាមទារឱ្យក្រុមហ៊ុនផ្ដល់ប្រាក់ឈ្នួល ១០០% និងអត្ថប្រយោជន៍ផ្សេងៗជូនកម្មករនិយោជិត នៅពេលក្រុមហ៊ុនគ្មានការងារឱ្យធ្វើ(ព្យួរកិច្ចសន្យាការងារ) ដោយគ្មានការអនុញ្ញាតពីក្រសួងការងារ**

- ក្រុមហ៊ុន សៅធន៌ បើរ ធ្លាប់បានព្យួរកិច្ចសន្យាការងារចំពោះកម្មករនិយោជិតមួយលើករួចមកហើយ គឺចាប់ពីថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៨ ដល់ថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០០៩ ដោយមានការយល់ព្រមពីអធិការការងារ និងដោយបានជូនដំណឹងដល់កម្មករនិយោជិតចំនួន០១ថ្ងៃមុនការព្យួរ។
- ក្នុងចំណោមកម្មករនិយោជិត៦០០នាក់ ដែលធ្វើការនៅក្នុងក្រុមហ៊ុន សៅធន៌ បើរ មានកម្មករនិយោជិតចំនួន៥៥៩នាក់ត្រូវបានក្រុមហ៊ុនព្យួរកិច្ចសន្យាការងារជាលើកទី២ ចាប់ពីថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០០៩ ដល់ថ្ងៃទី០៥ ខែមេសា ឆ្នាំ២០០៩ ដោយក្រុមហ៊ុនបានធ្វើពាក្យសុំទៅអធិការការងារនៅថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០០៩ដែរ តែគ្មានការឆ្លើយតប។ មូលហេតុនៃការព្យួរកិច្ចសន្យាការងារនេះ ដោយសារក្រុមហ៊ុនមិនបានទទួលការបញ្ជាទិញបណ្ដាលមកពីវិបត្តិសេដ្ឋកិច្ចពិភពលោក។
- ភាគីកម្មករនិយោជិតទទួលស្គាល់ថា សព្វថ្ងៃក្រុមហ៊ុនពិតជាគ្មានការងារ គ្មានអ្នកបញ្ជាទិញពិតប្រាកដមែន។
- ក្នុងការព្យួរកិច្ចសន្យាការងារលើកទី១នេះ ក្រុមហ៊ុនបានផ្ដល់ជូនកម្មករនិយោជិតនូវប្រាក់ថ្លៃជួលផ្ទះស្នាក់នៅចំនួន០៨ដុល្លារអាមេរិកក្នុងមួយខែ ប្រាក់ទ្រទ្រង់ជីវភាពចំនួន០៦ដុល្លារអាមេរិកក្នុងមួយខែ និងប្រាក់អតីតភាពការងារ តាមចំនួនឆ្នាំដែលកម្មករនិយោជិតបានធ្វើការនៅក្នុងក្រុមហ៊ុន។ ជាសរុបក្នុងកម្មករនិយោជិតម្នាក់ៗទទួលបានប្រាក់ចាប់ពី១៤ដុល្លារអាមេរិកទៅ១៩ដុល្លារអាមេរិកក្នុងមួយខែ។
- នៅក្នុងក្រុមហ៊ុន សៅធន៌ បើរ សព្វថ្ងៃ មានតែកម្មករនិយោជិតចំនួន៤១នាក់ប៉ុណ្ណោះ គឺប្រធានក្រុម និងថ្នាក់ដឹកនាំសហជីព៣០៦នាក់ ដែលមិនត្រូវបានក្រុមហ៊ុនព្យួរកិច្ចសន្យាការងារ។
- ភាគីកម្មករនិយោជិតនៅតែទាមទារប្រាក់ឈ្នួល១០០% និងអត្ថប្រយោជន៍ផ្សេងៗមានប្រាក់ទ្រទ្រង់ជីវភាពនៅក្នុងកំឡុងពេលដែលក្រុមហ៊ុនព្យួរកិច្ចសន្យាការងារលើកទី២ គឺចាប់ពីថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០០៩ ដល់ថ្ងៃទី០៥ ខែមេសា ឆ្នាំ២០០៩ ដោយលើកមូលហេតុថា ការព្យួរកិច្ចសន្យាការងារលើកទី២

នេះ គ្មានការអនុញ្ញាតពីអធិការការងារ និងជាការព្យួរកិច្ចសន្យាការងារខុសច្បាប់។ ដោយឡែកភាគីក្រុមហ៊ុននៅតែរក្សាជំហរថា នឹងផ្ដល់ជូនកម្មករនិយោជិត តែប្រាក់ថ្លៃជួលផ្ទះស្នាក់នៅចំនួន០៨ដុល្លារអាមេរិកក្នុងមួយខែ ប្រាក់ទ្រទ្រង់ជីវភាពចំនួន០៦ដុល្លារអាមេរិកក្នុងមួយខែ និងប្រាក់អតីតភាពការងារតាមចំនួនឆ្នាំដែលកម្មករនិយោជិតបានធ្វើការនៅក្នុងក្រុមហ៊ុនប៉ុណ្ណោះ ដោយសារក្រុមហ៊ុនពិតជាគ្មានអ្នកបញ្ជាទិញ ហើយក្រុមហ៊ុនកំពុងជួបវិបត្តិសេដ្ឋកិច្ចដែរ។

## **ហេតុផលសំរាប់ធ្វើសេចក្ដីសម្រេចៈ**

ក្រុមប្រឹក្សាអាជ្ញាកណ្ដាលនឹងពិចារណាថា តើការព្យួរកិច្ចសន្យាការងារលើកទី២ ចាប់ពីថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០០៩ ដល់ថ្ងៃទី០៥ ខែមេសា ឆ្នាំ២០០៩ ធ្វើឡើងត្រឹមត្រូវតាមច្បាប់ដែរ ឬទេ ?

ក្រុមប្រឹក្សាអាជ្ញាកណ្ដាលរកឃើញថា ក្រុមហ៊ុន សៅធន៍ បេរ បានព្យួរកិច្ចសន្យាការងារកម្មករនិយោជិតចំនួន៥៥៩នាក់ លើកទី ១ ចំនួន២ខែ គឺចាប់ពីថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០០៨ ដល់ថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០០៩ ដោយមានការយល់ព្រមពីអធិការកិច្ចការងារ។ ហើយនៅលើកទី២ ក្រុមហ៊ុនបានធ្វើលិខិត ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ ២០០៩ សុំទៅអធិការកិច្ចការងារ ដើម្បីព្យួរកិច្ចសន្យាការងារបន្តចំនួន២ខែបន្ថែមទៀត គឺចាប់ពីថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០០៩ ដល់ថ្ងៃទី០៥ ខែមេសា ឆ្នាំ២០០៩។ ប៉ុន្តែគ្មានការអនុញ្ញាតពីអធិការកិច្ចការងារឡើយ។

ច្បាប់ស្ដីពីការងារ មាត្រា៧១ ចំណុចទី១១ បានចែងថា *"កិច្ចសន្យាការងារត្រូវព្យួរដោយមូលហេតុដូចខាងក្រោម :*

*១១-ពេលណាដែលសហគ្រាសជួបការលំបាកផ្នែកសេដ្ឋកិច្ច ឬសំភារៈធ្ងន់ធ្ងរ ឬការលំបាកជាពិសេសណាមួយ ដែលនាំឱ្យព្យួរសកម្មភាពសហគ្រាសមិនលើសពី ពីរខែ។ ការព្យួរនេះត្រូវដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យរបស់អធិការការងារ ។"*

តាមខ្លឹមសារនៃមាត្រា៧១ ចំណុចទី១១ នេះ មានន័យថា ការព្យួរកិច្ចសន្យាការងារដោយមូលហេតុជួបការលំបាកផ្នែកសេដ្ឋកិច្ចនេះ មានរយៈពេលយ៉ាងយូរពីរខែ ហើយត្រូវមានការយល់ព្រមពីអធិការកិច្ចការងារថែមទៀត។

យោងតាមអង្គហេតុ ការព្យួរកិច្ចសន្យាការងារបន្តលើកទី២ ចំពោះកម្មករនិយោជិតចំនួន៥៥៩នាក់ បន្ថែមចំនួន២ខែទៀត ដោយគ្មានការយល់ព្រមពីអធិការកិច្ចការងារ និងរយៈពេលសរុបការព្យួរការងារទាំងពីរលើក គឺលើសពី២ខែបែបនេះ គឺផ្ទុយពីខ្លឹមសារក្នុងមាត្រា៧១ នៃច្បាប់ស្ដីពីការងារ។ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលយល់ឃើញថា ការព្យួរកិច្ចសន្យាការងារលើកទី២ ចាប់ពីថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០០៩ ដល់ថ្ងៃទី០៥ ខែមេសា ឆ្នាំ២០០៩ ចំពោះកម្មករនិយោជិតចំនួន៥៥៩នាក់ គឺជាការព្យួរកិច្ចសន្យាការងារមិនស្របច្បាប់។

ក្រុមប្រឹក្សាអាជ្ញាកណ្ដាលនឹងពិចារណាថា ការព្យួរកិច្ចសន្យាការងារមិនស្របច្បាប់ តើកម្មករនិយោជិត

មានសិទ្ធិទទួលបានប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេងៗដែរ ឬទេ ?

ក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងសំណុំរឿងមុនៗយល់ឃើញថា ការព្យួរកិច្ចសន្យាការងារមិនស្របច្បាប់ ចាត់ទុកដូចជាគ្មានការព្យួរកិច្ចសន្យាការងារ ហើយចាត់ទុកថា និយោជកមិនបានផ្តល់ការងារឱ្យកម្មករនិយោជិតធ្វើ ។ ដូច្នេះចំណេងកាតព្វកិច្ចរបស់និយោជក ដែលត្រូវផ្តល់ប្រាក់ឈ្នួលពេញនៅតែមានសុពលភាព។ ក្នុងករណីដែលព្យួរកិច្ចសន្យាមិនស្របច្បាប់ និយោជកត្រូវផ្តល់ប្រាក់ឈ្នួល១០០%ជូនកម្មករនិយោជិត។ (សូមមើលសំណុំរឿង*លេខ ២១/០៣-ឡូយ៉ាល់ ខេមបូឌា ហេតុផលនៃសេចក្តីសម្រេចចំណុចវិវាទទី៨, លេខ ៤៦/០៤-អ៊ីម និងវ៉េ ខេមបូឌា ហេតុផលនៃសេចក្តីសម្រេចចំណុចវិវាទទី១, លេខ ៦០/០៤-យូណាយធីតអាត ហេតុផលនៃសេចក្តីសម្រេចចំណុចវិវាទទី១ និងលេខ ៤៣/០៥-ប៊ូហ្គោ ហេតុផលនៃសេចក្តីសម្រេចចំណុចវិវាទទី១*) ។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលក៏យល់ឃើញដូចក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងសំណុំរឿងមុនៗដែរ គឺក្នុងករណីដែលព្យួរកិច្ចសន្យាមិនស្របច្បាប់ និយោជកត្រូវផ្តល់ប្រាក់ឈ្នួល១០០%ជូនកម្មករនិយោជិត ។

ចំពោះការទាមទារអត្ថប្រយោជន៍ផ្សេងទៀត គឺប្រាក់ទ្រទ្រង់ជីវភាព ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិនិត្យ និងពិចារណាថា តើកម្មករនិយោជិតមានសិទ្ធិទទួលបានប្រាក់ទ្រទ្រង់ជីវភាព ០៦ ដុល្លារអាមេរិកនេះ ឬទេ?

ចំណុចទី១ នៃសេចក្តីជូនដំណឹងលេខ ០៣២/០៨ កប/ស.ជ.ណ ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០០៨ ដែលបានចែងថា " *ផ្តល់ប្រាក់ឧបត្ថម្ភសម្រាប់ទ្រទ្រង់ជីវភាពរបស់កម្មករនិយោជិត ជាកូនជាង អ្នកធ្វើការម្តងម្កាល ឬអណ្តែត អ្នកសាកល្បង និងអ្នកពេញសិទ្ធិ ដែលធ្វើការនៅរោងចក្រ សហគ្រាស គ្រឹះស្ថានផ្នែកវាយនភ័ណ្ឌកាត់ដេរ និងផលិតស្បែកជើងក្នុងម្នាក់ៗចំនួន០៦(ប្រាំមួយ)ដុល្លារអាមេរិកក្នុង១ខែ ។ ប្រាក់ឧបត្ថម្ភនេះមិនត្រូវបានបូកបញ្ចូលធ្វើជាប្រាក់ឈ្នួលសុទ្ធសាធទេ (ប្រាក់ឈ្នួលគោល) ។*"

កំណត់ហេតុអង្គប្រជុំស្តីពីនីតិវិធីនៃការកំណត់ប្រាក់ឧបត្ថម្ភសម្រាប់ទ្រទ្រង់ជីវភាពរបស់កម្មករនិយោជិតផ្នែកឧស្សាហកម្មវាយនភ័ណ្ឌកាត់ដេរ និងផលិតស្បែកជើងចំនួន០៦(ប្រាំមួយ)ដុល្លារអាមេរិក ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០០៨ ចំណុចទី២ ដែលបានចែងថា "*២-ចំពោះកម្មករនិយោជិតទាំងអស់ ទាំងកម្មករនិយោជិតថ្មីដែលធ្វើការចាប់ពីខែបន្ទាប់ទៅ និងកម្មករនិយោជិតចាស់គ្រប់ប្រភេទ ត្រូវទទួលបានប្រាក់ឧបត្ថម្ភសម្រាប់ទ្រទ្រង់ជីវភាព កម្មករនិយោជិតពេញ គឺ ០៦ (ប្រាំមួយ) ដុល្លារអាមេរិក ដោយមិនកំណត់លក្ខខណ្ឌអ្វីឡើយ ។*"

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងមុនៗយល់ឃើញថា ពាក្យ "**ដោយមិនកំណត់លក្ខខណ្ឌអ្វីឡើយ**" នៅក្នុងកំណត់ហេតុនេះ សំដៅទៅលើការឈប់សម្រាកដោយគ្មានប្រាក់ឈ្នួល ដែលមានការអនុញ្ញាតពីនិយោជក។ ទោះបីកម្មការិនីសុំច្បាប់ឈប់សម្រាកបន្ថែមចំនួន០១ខែទៀតក៏ដោយ ក៏នៅមានសិទ្ធិទទួលបានប្រាក់ឧបត្ថម្ភទ្រទ្រង់ជីវភាពកម្មករនិយោជិតពេញចំនួន០៦ដុល្លារអាមេរិកដែរ ។(សូមមើលសំណុំរឿង*លេខ ១១៥/០៨-ហុងវ៉ាថ្មី ហេតុផលនៃសេចក្តីសម្រេចចំណុចវិវាទទី៣*) ។

នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលក៏យល់ស្របតាមការបកស្រាយរបស់ក្រុមអាជ្ញាកណ្ដាលមុនៗដែរ។ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលយល់ឃើញថា បើទោះបីជាការព្យួរកិច្ចសន្យាការងារត្រឹមត្រូវតាមច្បាប់ ឬមិនស្របច្បាប់ក៏ដោយ ក៏កម្មករនិយោជិតនៅតែទទួលបានប្រាក់ឧបត្ថម្ភទ្រទ្រង់ជីវភាពកម្មករនិយោជិតពេញចំនួន ០៦ ដុល្លារអាមេរិកនេះដែរ ពីព្រោះប្រាក់ឧបត្ថម្ភនេះសម្រាប់ផ្ដល់ឱ្យកម្មករនិយោជិតដោយគ្មានកំណត់លក្ខខណ្ឌ។

ដោយសំអាងលើអង្គហេតុ ភស្តុតាង ហេតុផល និងអង្គច្បាប់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលបង្គាប់ ដូចតទៅ :

## សម្រេច និង បង្គាប់

បង្គាប់ឱ្យក្រុមហ៊ុន សៅធនី បើរ ផ្ដល់ប្រាក់ឈ្នួល១០០%(មួយរយភាគរយ) និងប្រាក់ឧបត្ថម្ភទ្រទ្រង់ជីវភាពកម្មករនិយោជិតចំនួន០៦(ប្រាំមួយ)ដុល្លារអាមេរិកក្នុងមួយខែ ជូនកម្មករនិយោជិតចំនួន៩៥៩នាក់ ដែលត្រូវបានព្យួរកិច្ចសន្យាការងារចាប់ពីថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០០៩ ដល់ថ្ងៃទី០៥ ខែមេសា ឆ្នាំ២០០៩ ។

**ប្រភេទនៃសេចក្ដីបង្គាប់ : សេចក្ដីបង្គាប់មិនជាប់កាតព្វកិច្ច**

*សេចក្ដីបង្គាប់នេះនឹងក្លាយជាស្ថាពរ បន្ទាប់ពីថ្ងៃជូនដំណឹងអំពីសេចក្ដីបង្គាប់ចំនួន៨ថ្ងៃ បើសិនជាមិនមានភាគីណាមួយដាក់ពាក្យជំទាស់ជាលាយល័ក្ខណ៍អក្សរទៅរដ្ឋមន្ត្រីក្រសួងការងារ តាមរយៈលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្ដាលក្នុងរយៈពេលនេះទេ ។*

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្ដាល**

អាជ្ញាកណ្ដាលជ្រើសរើសដោយភាគីនិយោជក :

ឈ្មោះ : **ឈឹម ស៊ីរម្យ**

ហត្ថលេខា: ---------------------------------

អាជ្ញាកណ្ដាលជ្រើសរើសដោយភាគីកម្មករនិយោជិត :

ឈ្មោះ : **លឹម សុវណ្ណា**

ហត្ថលេខា: ---------------------------------

ប្រធានក្រុមអាជ្ញាកណ្ដាល :

ឈ្មោះ : **អ៊ាំង អេងជុង**

ហត្ថលេខា: ---------------------------------